មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0173**

**សម្ភាសន៍ជាមួយឈ្មោះ ប៉ុល ផាន ភេទស្រី អាយុ៥៣ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ “នារីកងចល័ត”**

**សព្វថ្ងៃរស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ហ៊ិន សុធានី**

**០០:២៦:៥៤**

**១៦ទំព័រ**

ធានី : ថ្ងៃនឹង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ធានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះ ខ្ញុំចង់សាកសួរពីប្រវត្តិរបស់មីង ដែលមីងបានឆ្លងកាត់កាលពីសម័យខ្មែរក្រហមយ៉ាងម៉េច ហើយប្រវត្តិរឿងរ៉ាវទាំងនេះ ខ្ញុំសុំយកមកចងក្រងធ្វើជាសៀវភៅទស្សនាវដ្តី ហើយនឹងសម្រាប់ឲ្យអ្នកស្រាវជ្រាវផ្សេងៗបានដឹងបានឮ ហើយខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបបានទេមីង?

ផាន : ចា៎! មានអីទេ ។

ធានី : មីងមានឈ្មោះអីដែរ?

ផាន : ខ្ញុំឈ្មោះ ប៉ុល ផន ។

ធានី : ប៉ុល ផន ឆ្នាំនឹងមីងអាយុប៉ុន្មានហើយ?

ផាន : ខ្ញុំ៥៣ ។

ធានី : មីងមានស្រុកកំណើតនៅណាដែរ?

ផាន : ស្រុកកំណើតនៅនេះ ។

ធានី : ស្រុកកំណើតនៅភូមិឃុំអី?

ផាន : ភូមិប៉ោយព្រីង ។

ធានី : ឃុំអីគេ?

ផាន : ឃុំព្រះនេត្រព្រះ ។

ធានី : ស្រុកអីគេ?

ផាន : ស្រុកព្រះនេត្រព្រះ ។

ធានី : ឪពុកមីងឈ្មោះអីគេ?

ផាន : ឈ្មោះ ប៉ុល ពុត ។

ធានី : គាត់នៅរស់ទេ?

ផាន : ទេ! គាត់ស្លាប់ ។

ធានី : ស្លាប់ពេលណា?

ផាន : ស្លាប់តាំងជំនាន់វៀតណាម ។

ធានី : ដោយសារអីដែរ?

ផាន : គាត់ឈឺ ។

ធានី : ចុះម្ដាយឈ្មោះអីគេដែរ?

ផាន : ប៉ុល ឆេត ។

ធានី : បងប្អូនគាត់?

ផាន : ចា៎!

ធានី : ម៉េចឈ្មោះប៉ុល ដូចគ្នាចឹង?

ផាន : ដាក់ប៉ុលទៅ ជីតាគាត់ដាក់ ទិន ឆេត ក៏បាន ដាក់ដូចគ្នា ។

ធានី : គាត់នៅរស់ទេ?

ផាន : ស្លាប់ ។

ធានី : ស្លាប់ដោយសារអីដែរ?

ផាន : ឈឺ ។

ធានី : នៅឆ្នាំប៉ុន្មានដែរ?

ផាន : តាំងពីវៀតណាម ។

ធានី : ពេលវៀតណាមចូលមកយើងមែន?

ផាន : ចា៎! ដែលវៀតណាមចូលមកហើយ ។

ធានី : ហើយបានប៉ុន្មានឆ្នាំ ។

ផាន : ចូលបាន២-៣ឆ្នាំដែរ ។

ធានី : ២-៣ឆ្នាំទាំង២នាក់ ស្លាប់ក្នុងពេលតែមួយ?

ផាន : ចា៎!

ធានី : ដំណាលគ្នា?

ផាន : ទេ! ឪខ្ញុំខូចមុន ។

ធានី : ខូចបានប៉ុន្មានខែ បានម្ដាយទៅដែរ?

ផាន : ២-៣ឆ្នាំដែរ ។

ធានី : ខូច២ឆ្នាំ បានម្ដាយខូច២ឆ្នាំដែរ?

ផាន : ចា៎! ម៉ែខ្ញុំមិនដឹងគាត់ឈឺអីទេ ស្រាប់តែអាជិតភ្លឺព្រឹកៗ គាត់ទៅបត់ជើង គាត់ដួលនៅនឹងស្រះ គាត់ដួលផ្កាប់មុខចេះ ក៏ស្លាប់ដាច់ដង្ហើម ។

ធានី : ចុះមីងមានបងប្អូនប៉ុន្មាននាក់?

ផាន : ប្អូនច្រើនណាស់ ប្អូន២នាក់ ៣នាក់ ៤នាក់ ។

ធានី : បងប្អូន៤នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ផាន : ស្រីទាំងអស់ ។

ធានី : ស្រីទាំង៤?

ផាន : ចា៎! ដល់បួសសង្ឃម្នាក់ នៅនេះ៣នាក់ សុទ្ធតែស្រី ។

ធានី : គាត់នៅរស់ទាំងអស់?

ផាន : ចា៎! នៅទាំងអស់ ។

ធានី : មីងរៀបការនៅឆ្នាំប៉ុន្មាន?

ផាន : រៀបគេ កាលវៀតណាមនៅ ។

ធានី : ចាំទេមីង ចាំឆ្នាំ?

ផាន : អត់បានចាំទេ អត់បានចាំឆ្នាំ ។

ធានី : កូនបងអាយុប៉ុន្មានហើយឥឡូវ?

ផាន : ៣០ជាងហើយ ៣៥ ។

ធានី : ចឹងតាំង៧៩មកមីងរៀបការ?

ផាន : ចា៎! យូរគ្រាន់ ។

ធានី : តាំងវៀតណាមចូលមកភ្លាម រៀបការភ្លាម?

ផាន : យូរគ្រាន់ដែរ ឡើង ។

ធានី : បើកូនមីងអាយុ៣៥ហើយ ឥឡូវយើងរាប់ពីនឹងទៅដល់៧៩ ៣៥ឆ្នាំ?

ផាន : បើនោះមិនទាន់៣៥ទេដឹង ២០ជាង បើមីងមួយនោះទើប២៨ មិនទាន់ដល់៣០ ដឹងទៅជា យ៉ាងណា ២៧អី ២៥ ។

ធានី ៖ អាចការតាំងពី ដូចថាវៀតណាមចូលមកបាន២-៣ឆ្នាំ?

ផាន ៖ នោះហើយ ដាក់២៥ទៅ ។

ធានី ៖ គ្រួសារមីងឈ្មោះអីគេ?

ផាន ៖ លិញ ធំ ។

ធានី ៖ គាត់ធ្វើអីដែរ ឈឺ?

ផាន ៖ ឈឺ អត់បានធ្វើអីទេ ។

ធានី ៖ មីងមានកូនប៉ុន្មាននាក់?

ផាន ៖ ៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ផាន ៖ ប្រុសម្នាក់ ស្រី៣ ។

ធានី ៖ មីងបានរៀន បានសូត្រអីទេ?

ផាន ៖ ខ្ញុំរៀនពីសង្គម រៀនមិនចេះអស់ ។

ធានី ៖ រៀនដែរ តែរៀនអត់ចេះ?

ផាន ៖ ចាំ! រៀនបានតិច ។

ធានី ៖ រៀនអត់ចេះ?

ផាន ៖ ចាំ!

ធានី ៖ ចុះមីងអាចជួយរៀបរាប់ប្រវត្តិរបស់មីង តាំងមីងនៅតូច រហូតដល់សម័យខ្មែរក្រហម ហើយរហូតមកដល់ឥឡូវ មីងជួយរៀបរាប់បានទេ?

ផាន ៖ មានអី ។

ធានី ៖ ជួយប្រាប់តិចមើលថាម៉េចខ្លះ កាលនៅតូចមីងធ្វើអីខ្លះ ហើយកាលនឹងយ៉ាងម៉េច?

ផាន ៖ អូ! កាលនៅតូចៗនៅជាមួយម៉ែ ។ ខ្ញុំនៅតូចៗជាមួយម៉ែ ពីដើមខ្ញុំកាប់អុស កាប់អីលក់ អុំទូកទៅលក់ឯមង្គលបូរី ។

ធានី ៖ ម៉េចទៀតទៅ?

ផាន ៖ ក៏ដល់វាអត់ ក៏ខ្ញុំទៅនៅជាមួយគេៗពីសង្គមមិញនោះ ។ កាប់អុសទៅលក់ អុំទូកទៅលក់មង្គលបូរី ដល់ធំគ្រាន់ក៏ខ្ញុំទៅនៅជាមួយគេ អត់បានធ្វើអីទេ ។

ធានី ៖ មីងកាលនឹងមីងទៅនៅជាមួយអ្នកណាគេ?

ផាន ៖ នៅជាមួយអ្នកមង្គលបូរី ។

ធានី :	ឈ្មោះអីគេស្គាល់?

ផាន :	មិនស្គាល់ទេ ភ្លេចអស់ហើយ ពីមុននៅតូច ។

ធានី :	កាលនឹងអាយុប៉ុន្មាន?

ផាន :	កាលនៅតូចនោះអាយុជាង១០ឆ្នាំ ពីសង្គម នៅជាមួយគេ ។ ក៏ធំគ្រាន់នៅជាមួយម៉ែឪមិន បានធ្វើអីទេ កាប់អុសលក់ ពុកអុស ដឹករទេះទៅយកទៅលក់ ដល់ធំគ្រាន់ក៏ទៅនៅជាមួយ គេៗរកឲ្យទៅនៅជាមួយគេ អត់ពីដើមមិញ ។

ធានី :	ម៉េចទៀតមីង បន្ទាប់ពីនៅជាមួយគេហើយ ទៅណាទៀត?

ផាន :	ដែលនៅជាមួយគេក៏គ្មានទៅណា មកផ្ទះ ។

ធានី :	ម៉េចបានមកផ្ទះ?

ផាន :	ឈប់នៅជាមួយគេ ក៏មកនៅផ្ទះជាមួយម៉ែឪច្រូតស្រូវ ធ្វើស្រែធ្វើអី ។

ធានី :	ម៉េចបានឈប់នៅជាមួយគេ?

ផាន :	ឈប់នៅក៏មកនៅជាមួយម៉ែច្រូតស្រូវអី ។

ធានី :	ហើយម៉េចទៀតទៅ?

ផាន :	នៅជាមួយម៉ែឪធ្វើស្រែ ។

ធានី :	ធ្វើស្រែហើយធ្វើអី?

ផាន :	ធ្វើស្រែ កាប់អុស កាប់អីលក់ប៉ុននឹង ។

ធានី :	មិនមែនទេមីង ចឹងនៅពេលមីងធ្វើស្រែធ្វើអីចឹង ពេលណាដែលប្រជាជនថ្មីជម្លៀសមកភូមិ យើង?

ផាន :	ពួកអ្នកថ្មី គេជម្លៀសមកក៏គេទៅ ។

ធានី :	គេទៅណា?

ផាន :	គេទៅស្រុកគេវិញ ។

ធានី :	ចឹងនិយាយថា មីងនៅធ្វើស្រែនៅដល់ពេលណាបានមានឃើញអ្នកថ្មីនឹង ជម្លៀសមកភូមិ មីងនៅពេលណា នៅឆ្នាំប៉ុន្មាន?

ផាន :	ចា៎! ហោ៎! មិនដឹងផង ។

ធានី :	ប៉ុន្តែមានឃើញអ្នកថ្មីមក?

ផាន :	ចា៎!

ធានី ៖ ពេលនឹងគេមានឲ្យយើងប្រមូលអីៗរបស់អ្នកថ្មីនឹងអត់ ឬក៏មីងអ្នកប្រមូលខ្លួនឯង គេតាមប្រមូលទ្រព្យសម្បត្តិ?

ដាន ៖ អត់ទេ ។ ពួកខ្ញុំកាលដែលគេអ្នកថ្មី កាលដែលវៀតណាមចូលនឹង ។

ធានី ៖ ដែលខ្មែរក្រហមចូល?

ដាន ៖ នោះឯង កាលដែលខ្មែរក្រហមចូល កាលនោះខែច្រូតខ្ញុំទៅនៅរនាម អ្នកថ្មីគេនៅនេះទៅដល់នេះគេចេញទៅវិញអស់ហើយ ។ ខ្ញុំអត់ដឹង ខ្ញុំគ្មានបានប្រមូលបានអីទេ នៅតែរនាមស្រែនោះ ។

ធានី ៖ រនាម?

ដាន ៖ ចាំ!

ធានី ៖ នៅស្រែធ្វើអីគេ?

ដាន ៖ នៅស្រែច្រូតស្រូវ ។

ធានី ៖ ហើយយកឲ្យអ្នកណាគេ ស្រូវនឹង?

ដាន ៖ ច្រូតស្រូវនោះ ស្រូវច្រូតដឹងឲ្យអ្នកណាទេ របស់គេខ្ញុំមិនដឹងផង បើខ្ញុំទៅនៅជាមួយគេទៅ នៅរនាម ។

ធានី ៖ តែមីងអត់ចាំឈ្មោះអ្នកដែលមីងទៅនៅជាមួយ?

ដាន ៖ អូ! ខ្ញុំនៅជាមួយយាយ ។

ធានី ៖ យាយឈ្មោះអីគេ?

ដាន ៖ យាយយីន ។

ធានី ៖ យាយបង្កើតរបស់មីង ឬក៏ម៉េច?

ដាន ៖ យាយនោះ ម៉ែក្មេក ។

ធានី ៖ កាលនឹងមីងមិនទាន់រៀបការផង ម៉េចក៏មានម៉ែក្មេក?

ដាន ៖ អូ! កាលនោះខ្ញុំបាន កាលនោះខ្ញុំបានការអាពត ។

ធានី ៖ មីងការអាពត?

ដាន ៖ ចាំ! ខ្ញុំបានការអាពត ។

ធានី ៖ ពេលណាខ្មែរក្រហមចូលដល់ភូមិយើង ចាំទេ?

ដាន ៖ ចូលដល់ភូមិយើង ចូលដល់រនាមៗបានគេចូលមកនេះទៅ ខ្ញុំអត់បាននៅភូមិទេ ខ្ញុំនៅតែស្រែ ។

ធានី : នៅស្រែម៉េចទៀត?

ផាន : ដល់នៅស្រែៗដល់យូរៗបានឡើងមកនៅក្នុងភូមិ កាលនោះខ្ញុំនៅជាមួយយាយម៉ែក្មេកខ្ញុំ នៅជាមួយគ្នា ។ កាលនោះខ្ញុំបានទៅក្រោយ ។ ដល់អាប្ដីខ្ញុំមុននោះគេយកវ៉ៃៗចោល ។

ធានី : កាលពេលមីងនៅធ្វើស្រែ ចឹងមីងរៀបការឆ្នាំប៉ុន្មាន?

ផាន : ខ្ញុំកាលដែលខ្ញុំរៀបការ កាលអាពត ។

ធានី : នឹងរៀបការអាពតនឹង ពេលណា?

ផាន : មិនដឹងឆ្នាំប៉ុន្មាន ។

ធានី : កាលនឹងប្រជាជនថ្មីចូលនៅ?

ផាន : នៅអត់ទាន់ចូលទេ ។

ធានី : កាលការនឹងប្រជាជនថ្មីអត់ទាន់ចូលទេ?

ផាន : ទេ!

ធានី : សម័យនឹង មានទាហានលន់ នល់ ទាហានខ្មែរក្រហមអីអត់?

ផាន : មាន ។

ធានី : កាលនឹងមានទាហានលន់ នល់ នៅភូមិយើងដែរ?

ផាន : ចា៎! នោះហើយ ភូមិគេចូលពួកនិរតីចូលអីហើយ ។ ពួកនិរតីចូលមកខ្ញុំរៀបការរួចហើយ ។

ធានី : ចុះខាងពួកបូព៌ា ពួកពាយ័ព្យ ពួកបស្ចឹមអី?

ផាន : ហ្នឹងឯងដែលពួកនិរតីចូលមកនេះ ។ ដល់ចូលមកខ្ញុំរៀបការរួចហើយ ។ រៀបការរួចទៅគេ យកគ្រួសារខ្ញុំទៅសម្លាប់នោះ ។

ធានី : គ្រួសារមីងធ្វើអីគេ បានគេយកគ្រួសារទៅសម្លាប់?

ផាន : អត់មានធ្វើអីទេ គេឲ្យទៅដឹកឈើ គេសួរៗអីថាអីទេ កាលនឹងគ្រួសារខ្ញុំដែលពួកនិរតីចូល មកដែលគេវ៉ៃមនុស្សនឹងកាំភ្លើង ។

ធានី : កាលនឹងគ្រួសារមីងធ្វើអីគេ បានពួកនិរតីសម្លាប់គាត់ចឹង?

ផាន : ថាគេវ៉ៃមនុស្សខ្លាំងពេកគាត់ខ្លាចៗមកផ្ទះ គាត់រត់មកផ្ទះ កាលនឹងខ្ញុំនៅព្រៃមាន់ មិននៅ ភូមិនេះទេណា ។ ដល់នេះក៏ខ្លាចគាត់មកផ្ទះៗទៅ គេរក ដល់គាត់មកលេងផ្ទះម៉ែគាត់ ។ ដល់គាត់ទៅវិញៗ គេថាយើងរត់ ។ គេឲ្យយើងទៅដឹកឈើនៅដូនជ្រៃ គេចាប់តាមផ្លូវ ក៏ គេយកវ៉ៃចោល ។

ធានី : ម៉េចបានមីងដឹង?

ដាន ៖	មិនដឹង ។

ធានី ៖	អ្នកណាគេប្រាប់មីងបាន មីងដឹង?

ដាន ៖	អ្នករត់ជាមួយគ្នា ។

ធានី ៖	អ្នកណាគេ ឈ្មោះអីគេ?

ដាន ៖	អ្នករត់ជាមួយគ្នា ដឹងគេឈ្មោះអី គាត់និយាយចុះឯង និយាយប្រាប់ម៉ែ គាត់មកៗផ្ទះ គាត់ខ្លាចឃើញគេវ៉ៃពេក គាត់មកផ្ទះ ។ ដល់គាត់មកផ្ទះ យើងទៅវិញ ដល់គេរកយើង ដល់យើងទៅវិញ គេថាយើងរត់ៗ ក៏គេចាប់យើងៗមិនបានធ្វើអីទេ ។

ធានី ៖	ប្ដីមីងឈ្មោះអីគេ?

ដាន ៖	ឈ្មោះ ទិន ។

ធានី ៖	ឪពុកគាត់អីគេ?

ដាន ៖	ឪពុកគាត់ឈ្មោះ វិន ។

ធានី ៖	វិន ទិន?

ដាន ៖	ហ្នឹង ។

ធានី ៖	ម៉េចបានគាត់បានឃើញគេសម្លាប់មនុស្ស បានគាត់ខ្លាច?

ដាន ៖	និយាយមិនឃើញម៉េច កន្លែងដែលនៅ កន្លែងផ្ទះម៉ាដួលបេះ ។

ធានី ៖	គាត់នៅណា?

ដាន ៖	នៅព្រៃមាន់ ផ្ទះម៉ាដួរបេះ ល្ងាចឡើងក៏គេលីជនីកទៅកន្លែងជម្រុកធំ ។

ធានី ៖	មីងបានឃើញដែរអត់?

ដាន ៖	ឃើញតែគេដើរលីជនីកទៅ ។

ធានី ៖	និយាយពីប្ដីមីងដែលរត់មកផ្ទះនោះ?

ដាន ៖	ដែលមកផ្ទះបាន២-៣ថ្ងៃទៅ ។

ធានី ៖	អត់ទេ ចង់និយាយថា ប្ដីមីងមិនប្រាប់ថា ប្ដីមីងរត់មកផ្ទះនឹង ដោយសារឃើញគេសម្លាប់មនុស្សច្រើនពេកខ្លាចក៏រត់មកផ្ទះ?

ដាន ៖	ចាំ!

ធានី ៖	ខ្ញុំចង់សួរថាម៉េចបានប្ដីមីងបានឃើញរឿងគេសម្លាប់មនុស្សនឹងច្រើន?

ដាន ៖	ដឹងៗ បើយប់ឡើង ល្ងាចឡើងលីជនីកទៅជម្រុកធំ ។

ធានី ៖	ប្ដីមីងនៅព្រៃមាន់ដែរ?

ផាន :	ចា៎! នៅព្រៃមាន់ ។

ធានី :	តើមីងបានឃើញដែរ?

ផាន :	ឃើញ ។

ធានី :	តែមីងអត់រត់មកផ្ទះទេ ហើយប្ដីមីងរត់មកផ្ទះ?

ផាន :	ចា៎! ខ្ញុំអត់បានរត់ ខ្ញុំនៅតែក្នុងផ្ទះ ។ ល្ងាចឡើង ឃើញគេលីជនឹកទៅអាជជ្រុកមុខផ្ទះ ជជ្រុកធំ ។

ធានី :	ហើយមីងអត់ខ្លាចទេ?

ផាន :	ខ្លាចៗ តែយើងអត់ហ៊ាន ។

ធានី :	តែប្ដីម៉េចរត់មក?

ផាន :	ចុះគាត់ខ្លាច ។

ធានី :	រត់មកផ្ទះនេះ នៅស្រុកយើងនេះ ឬក៏រត់មកផ្ទះមីង?

ផាន :	មកស្រុកយើង មកផ្ទះគាត់ប៉ោយសំរោង ។

ធានី :	គាត់ខ្លាច?

ផាន :	ចា៎! គាត់ខ្លាច ដល់នេះទៅ ដល់គេរកយើងទៅគេបង្គាប់ឲ្យយើងទៅជីកនេះជីកនោះ គេចាប់ យើងតាមផ្លូវ យកវៃចោល ។

ធានី :	ចុះមីងរៀបការនឹង កាលនឹងមានគេចាប់ដៃចាប់អី ឬយ៉ាងម៉េច?

ផាន :	ចា៎! កាលគេរៀបម៉ាកងៗច្រើនណាស់ ដូចយើងអ្នកណាត្រូវរៀបការក៏គេហៅមកអង្គុយ ទាំងអស់គ្នាច្រើន ។

ធានី :	យ៉ាងម៉េចខ្លះមីងអាចជួយប្រាប់ខ្ញុំបានទេ? ការយ៉ាងម៉េច គេឲ្យរៀបការយ៉ាងម៉េច?

ផាន :	មានការអី គ្រាន់យើងមកបើកវគ្គ យើងអង្គុយចេះ អង្គុយបើកវគ្គ ។

ធានី :	ចង់និយាយថា ដំបូង ម៉េចបានមីងដឹងថាមីងការ គេមកប្រាប់មីងថាម៉េច បានមីងត្រូវទៅ ការជាមួយគាត់ ដូចថាគាត់ស្នើមីង ឬក៏គេចាត់តាំងឲ្យទៅចឹង?

ផាន :	គេស្នើ គេចាត់តាំងទៅ គេប្រាប់ ។

ធានី :	គេប្រាប់ថាម៉េច?

ផាន :	គេប្រាប់ថា ដែលគេចង់ គេប្រាប់យើងដល់ពេលគេបើកវគ្គទៅ ក៏គេប្រាប់យើងឲ្យយើង ទៅ ។

ធានី :	ការនឹង មីងចង់រៀបអត់?

ផាន ៖ ចា៎! ដែលគេស្នើទៅ យកគេទៅ។ ដល់ពេលបើកវគ្គ ក៏គេហៅ។

ផានី ៖ ចង់និយាយថា មីងពេញចិត្តនឹងចង់រៀបការជាមួយគាត់អត់ កាលពេលនឹង ស្រឡាញ់គាត់អត់?

ផាន ៖ ចា៎! មានអី។

ផានី ៖ ស្រឡាញ់គាត់ដែរ?

ផាន ៖ ចា៎!

ផានី ៖ ហើយកាលនឹងការប៉ុន្មានគូ?

ផាន ៖ ច្រើន ដែលទៅតិច បើកវគ្គម្ដង១ដែលតិច មានដែលបើកវគ្គទេ។

ផានី ៖ ប៉ុន្មាននាក់?

ផាន ៖ ៤-១០-២០។

ផានី ៖ បើកវគ្គអីគេអានឹង?

ផាន ៖ អាគេហៅបើកវគ្គ។

ផានី ៖ បើកវគ្គរៀបការ ៤-១០-២០គូ?

ផាន ៖ ចា៎!

ផានី ៖ ហើយអ្នកណាគេ អ្នកបើកកម្មវិធីការនឹង?

ផាន ៖ អឺ! ដែលស្គាល់ទេ ដឹងគេទៅណាទេ។

ផានី ៖ ចុះអ្នកណាគេអ្នកចាត់តាំងមីងឲ្យការជាមួយគាត់ អ្នកណាគេ អ្នកប្រាប់ថាថ្ងៃនឹងការហើយ?

ផាន ៖ ដែលចាំបានទេ ភ្លេច។

ផានី ៖ ចុះពេលការចឹងគេធ្វើពិធីយ៉ាងម៉េច មីងមានខោអាវថ្មីអត់ ឬមួយមីងពេលនឹងខោអាវចាស់ៗដដែល ឬក៏យ៉ាងម៉េច គេមានធ្វើពិធីអីទេ?

ផាន ៖ ទេ! គ្រាន់តែហៅ។

ផានី ៖ ដូចថាយើងនៅស្រុកយើងរាល់ថ្ងៃ យើងមានការយើងមានអាចារ្យ មានអីគេឲ្យពរអីចឹង១ ហើយដល់សម័យនឹងមានចឹងអត់?

ផាន ៖ អត់។

ផានី ៖ ហើយអត់គេធ្វើយ៉ាងម៉េច?

ផាន ៖ គ្រាន់តែគេបើកប្រជុំ គេនិយាយពីនេះពីនោះ។

ធានី ៖ ពីនេះពីនោះ និយាយពីអី មីងចាំ?

ផាន ៖ អូ! ដឹងគេនិយាយអីទេ អ្នកណាដឹងបានរាប់ឆ្នាំ តែសព្វថ្ងៃម៉ាឆ្នាំ២ឆ្នាំ ភ្លេចអស់ ។

ធានី ៖ ភ្លេចអស់ហើយអត់ចាំទេ?

ផាន ៖ នៅចាំខ្លះៗ ។

ធានី ៖ ចុះមីងទៅលើកទំនប់ត្រពាំងថ្មពេលណា?

ផាន ៖ លើកទំនប់នឹង ទៅចំណាំមិនបានទេ ។

ធានី ៖ ចុះម៉េចមីងដឹងថាទៅលើកទំនប់ត្រពាំងថ្ម?

ផាន ៖ ចំណាំមិនបានខែណា ឆ្នាំណា ចំណាំមិនបានគេឲ្យទៅ ។

ធានី ៖ ចុះកាលនឹងមីងថា មីងធ្វើការនៅព្រៃមាន់ លើកទំនប់នៅព្រៃមាន់ហើយ បានទៅត្រពាំងថ្ម ឬក៏ទៅត្រពាំងថ្មបានលើកទំនប់ ។ មួយណាមុន?

ផាន ៖ លើកទំនប់ៗត្រពាំងថ្ម ។

ធានី ៖ ត្រពាំងថ្ម ហើយបានទៅព្រៃមាន់?

ផាន ៖ ចាំ!

ធានី ៖ ចឹងកាលទៅលើកទំនប់នៅត្រពាំងថ្មនឹង អ្នកណាគេចាត់តាំងឲ្យមីងទៅ?

ផាន ៖ គេអ្នកប្រធាន ។

ធានី ៖ ឈ្មោះអីគេ?

ផាន ៖ ខ្ញុំមិនស្គាល់ទេ សួរឈ្មោះមិនដែលចាំទេ ។

ធានី ៖ ចុះប្រធានកងមីង អ្នកណាគេ?

ផាន ៖ ប្រធានកងក៏អត់ស្គាល់ ។

ធានី ៖ គាត់មកពីណាវិញ កាលនឹងប្រធានកងមីង?

ផាន ៖ អត់ដឹងគេមកពីណាមកពីណែ ដែលដឹង បើគេចេះតែចាត់តាំង ។

ធានី ៖ ចឹងមីងទៅលើកទំនប់ត្រពាំងថ្មនឹងម៉េចដែរ គេឲ្យធ្វើការងារយ៉ាងម៉េចខ្លះនៅនឹង លើកយ៉ាងម៉េចអីម៉េច?

ផាន ៖ លើកដី កាប់ដី ។

ធានី ៖ ប៉ុន្មានម៉ែត្រក្នុងម៉ាថ្ងៃគីប?

ផាន ៖ មិនដឹងប៉ុន្មានម៉ែត្រគីបទេ ចេះតែលើកឲ្យតែទំនប់ខ្ពស់ ។

ធានី ៖ គេមានវាស់ម៉ែត្រគីបឲ្យមីងកាប់អត់?

ផាន ៖ អត់វាស់ ។

ធានី ៖ អត់វាស់ទេ ធ្វើតាមសំរួល?

ផាន ៖ ចា៎!

ធានី ៖ ចឹងមីងលើករួចពេលណា លើកទៅ?

ផាន ៖ ចា៎!

ធានី ៖ ចឹងម៉ោងសម្រាកធ្វើស្មានណា?

ផាន ៖ ព្រឹកឡើងដល់ពេលថាពេលហូបបាយឡើងទៅ ។

ធានី ៖ ចង់និយាយថាងើបពីព្រលឹមម៉ោងប៉ុន្មាន យើងងើបទៅធ្វើ?

ផាន ៖ ព្រឹកឡើង ។

ធានី ៖ ភ្លឺហើយ?

ផាន ៖ ចា៎!

ធានី ៖ បានមីងទៅធ្វើ?

ផាន ៖ ចា៎!

ធានី ៖ ធ្វើដល់ថ្ងៃត្រង់ ក៏សម្រាក?

ផាន ៖ ចា៎! សម្រាក ។

ធានី ៖ សម្រាកហើយធ្វើដល់ពេលណាទៀត?

ផាន ៖ ថ្ងៃល្ងាចក៏ឈប់ ។

ធានី ៖ ថ្ងៃល្ងាចឈប់ហើយលែងធ្វើ?

ផាន ៖ ចា៎!

ធានី ៖ មីងដឹងទំនប់ត្រពាំងថ្មនៅណា?

ផាន ៖ នៅត្រពាំងថ្មនោះ ។

ធានី ៖ នៅខាងណា?

ផាន ៖ នៅខាងជើង ទៅខាងកើត ។

ធានី ៖ ទំនប់នឹងធំទេ?

ផាន ៖ ចា៎! ធំ ។

ធានី ៖ ហើយចុះមីងទៅដល់ ឃើញទំនប់នឹងយ៉ាងម៉េច រូបរាងវា មានទឹកមានអី?

ផាន ៖ មកទំនប់នេះធំ អាងទឹក ។

ធានី ៖ ចង់និយាយថា ពេលដែលមីងថាបានទៅលើកទំនប់នឹង?

ផាន ៖ ចាំ!

ធានី ៖ តែសួរថា ពេលនឹងមីងទៅដល់ភ្លាមនឹង ឃើញទំនប់នឹងយ៉ាងម៉េច របៀបដូចថាយើងទៅធ្វើស្រែ យើងទៅដល់ស្រែធម្មតាយើងទៅដល់ស្រែ យើងត្រូវភ្ជួរដី ប៉ុន្តែចង់សួរមីងថាពេលដែលមីងទៅដល់ទំនប់នឹង ។ ពេលមីងទៅដល់ដំបូង មីងឃើញទំនប់នឹងយ៉ាងម៉េច វាមានទំនប់ពីមុនចាស់នៅសល់ហើយ យើងលើកបន្ថែមទៀត ឬយ៉ាងម៉េច?

ផាន ៖ ខ្ញុំលើកបន្ថែមទៀត ។

ធានី ៖ បានន័យថាទំនប់នឹងធ្វើមុនហើយ ហើយមីងគ្រាន់ធ្វើបន្តទៀតទេ?

ផាន ៖ ចាំ! យើងធ្វើដូចទំនប់តូច យើងលើកឲ្យធំ ។

ធានី ៖ គ្រាន់មីងទៅដល់ឃើញទំនប់នឹងតូច ហើយបន្ទាប់មកលើកវាឲ្យជាទំនប់ធំទៅ?

ផាន ៖ ចាំ! ធំណាស់ ខ្ពស់ណាស់ ។

ធានី ៖ ប៉ុន្មានម៉ែត្រទៅដឹងទេ?

ផាន ៖ មិនដឹងជាប៉ុន្មានម៉ែត្រទេ ។

ធានី ៖ លើកម៉ាថ្ងៃប៉ុន្មានក៏អត់ដឹងដែរ?

ផាន ៖ ចាំ!

ធានី ៖ ចឹងហូបចុកម៉េចដែរ?

ផាន ៖ ហូបចុកមានអីធម្មតាទាំងអស់ ។ ធម្មតាគេឲ្យអង្ករដាំហូបទៀត ។

ធានី ៖ នៅទំនប់នឹង ឲ្យអង្ករដាំហូបទៀត?

ផាន ៖ ចាំ! នឹងហើយ ។

ធានី ៖ ធ្វើប៉ុន្មាននាក់ មីងចាំទេ?

ផាន ៖ ធ្វើដូចជាម៉ាក្រុមៗ៨-១០នាក់ ។

ធានី ៖ នៅទំនប់នឹង ទំនប់ត្រពាំងថ្ម មិនមែនទំនប់ធម្មតាទេ?

ផាន ៖ ចាំ! នោះហើយទំនប់ធំ ។

ធានី ៖ ប៉ុន្មាននាក់ម៉ាក្រុម?

ផាន ៖ ម៉ាក្រុមដូនណា១០នាក់ ។

ធានី ៖ ១០នាក់ គេឲ្យបាយហូប?

ផាន ៖ ចាំ!

ធានី ៖ គេឲ្យអង្ករប៉ុន្មានកំប៉ុង?

ផាន ៖ អង្ករម្តង៥០ ក៏យើងនៅដាំហូបទៅ ។

ធានី ៖ នៅហូបប៉ុន្មានខែ?

ផាន ៖ ឲ្យហូបឡើង៨-១០ខែ ទំនប់នឹងធំណាស់ កំពស់ឡើងទំនប់នឹង ។

ធានី ៖ ហើយហូបចុកអីធម្មតា?

ផាន ៖ ចាំ!

ធានី ៖ ចុះការរស់នៅ ស្នាក់នៅណាវិញ?

ផាន ៖ នៅនឹងបៀតភូមិគេ ។

ធានី ៖ បៀតភូមិកន្លែងណាវិញ?

ផាន ៖ ភូមិត្រពាំងថ្ម ។

ធានី ៖ ភូមិត្រពាំងថ្មនៅណា?

ផាន ៖ ចាំ! ដូចជានៅភូមិគេចេះ យើងចេញទៅមាត់វាល ។

ធានី ៖ ចុះហូបចុកអីធម្មតា ចុះមានទឹកហូបគ្រប់គ្រាន់ទេ?

ផាន ៖ ចាំ! ទឹកអីក៏មាន ។

ធានី ៖ មានគ្រប់គ្រាន់ទាំងអស់?

ផាន ៖ ហ្នឹងហើយ ។

ធានី ៖ បានទឹកមកពីណា?

ផាន ៖ ទឹកនៅបៀតភូមិគេ ។

ធានី ៖ ភូមិអីគេ ភូមិនឹង?

ផាន ៖ ភូមិត្រពាំងថ្ម ដូចយើងភូមិចេះ ហើយយើងចេញទៅវាល លើកទំនប់នៅមាត់វាលគេក្រៅពីភូមិ ។

ធានី ៖ ចុះមីងទៅលើកទំនប់នៅព្រៃមាន់នឹងម៉េចដែរ?

ផាន ៖ មានម៉េច ។

ធានី ៖ ដូចគ្នាដែរ?

ផាន ៖ ចាំ! នោះហើយ ។

ធានី ៖ ធ្វើយ៉ាងម៉េចដូចគ្នានឹង?

ផាន ៖ ទំនប់ព្រៃមាន់ កាលមុនខ្ញុំលើកទំនប់នឹង ខ្ញុំមិនបាននៅលើកទំនប់ទេ ខ្ញុំបានគ្រួសារ ក៏គេឲ្យទៅនៅនោះ ។

ធានី ៖ ទៅនៅណា ព្រៃមាន់?

ផាន ៖ ចា៎! ព្រៃមាន់ ។

ធានី ៖ ចឹងមីងរៀបការពេលទៅព្រៃមាន់?

ផាន ៖ ចា៎! ខ្ញុំបានគ្រួសារ គេឲ្យទៅនៅនឹង ។

ធានី ៖ ចឹងមីងស្គាល់មេក្រុមមីងដែលធ្វើការនៅទំនប់ត្រពាំងថ្មនឹងអត់ដឹងទេ?

ផាន ៖ អត់ស្គាល់ទេ ។

ធានី ៖ អត់ដឹងអ្នកណាគេទេ?

ផាន ៖ ចា៎! មិនដែលស្គាល់ទេ ចុះបើខ្ញុំដើរចល័ត ឧបមាថាគេឲ្យខ្ញុំទៅត្រពាំងថ្ម ឲ្យខ្ញុំទៅច្រូតស្រូវ ឲ្យខ្ញុំទៅដកសំណាប ខ្ញុំមិនដែលស្គាល់ទេ ។

ធានី ៖ ចុះមីងថានៅទំនប់ត្រពាំងថ្មនៅដល់៣ខែ?

ផាន ៖ ចា៎! បើខ្ញុំអ្នកដើរចល័ត ។

ធានី ៖ ដើរចល័ត៣ខែ?

ផាន ៖ ចា៎!

ធានី ៖ ជួនកាលទៅច្រូតស្រូវ ជួនកាលទៅនេះទៅនោះ ជួនកាលទៅលើកទំនប់ត្រពាំងថ្មម៉ាភ្លែតទៅ?

ផាន ៖ ចា៎! នោះហើយ ។

ធានី ៖ ទៅនៅលើកទំនប់នឹង ប្រហែលប៉ុន្មានដែរ មានចាំ?

ផាន ៖ ប្រហែលជាម៉ាខែប៉ុននោះ ។

ធានី ៖ ប៉ុន្តែម៉ាខែនឹងគេឲ្យបាយហូប ឬមួយយើងដាំជាក្រុម?

ផាន ៖ ដាំជាក្រុម គេឲ្យអង្ករ យើងដាំហូប ។

ធានី ៖ បើយើងដាំទៅ យើងមានពេលណាលើកទំនប់ទៅ បើទំនប់ធំ?

ផាន ៖ បើយើងក្រោកដាំ ខ្ញុំអ្នកដើរចល័ត ឧបមាថា យើងទៅច្រូតស្រូវចេះទៅច្រូត គេឲ្យទៅដកសំណាបនៅត្រពាំងថ្មចេះ ។

ធានី ៖ ចុះកងចល័តរបស់មីង កងចល័តអីគេ?

ផាន ៖ មិនដឹងកងចល័តស្តីទេ ខ្ញុំមិនដែលចាំទេ ។

ធានី ៖ កងចល័តតំបន់ កងចល័តពិសេស កងចល័តភូមិភាគ កងចល័ត?

ផាន ៖ ដឹងចល័តអីទេ ដល់ពេលខ្ញុំ ខាងគេប្រើឲ្យទៅនេះក៏ទៅៗ ។

ធានី ៖ អ្នកណាគេអ្នកប្រើមីងបាន?

ផាន ៖ មិនដឹងជាអ្នកណាគេ បើខ្ញុំមិនដែលស្គាល់ ។ ជួនណាខែច្រូតចេះ គេឲ្យទៅខាងច្រូតទៅ ពេលខាងដកសំណាបទៅដកសំណាប ពេលទៅស្ទូងៗទៅ ហើយដើរចល័ត ។ ដឹងតែរឿង ដើរចល័ត គេប្រើៗដឹងតែទៅ ។

ធានី ៖ ចុះមានការលំបាកអីអត់ទេ?

ផាន ៖ លំបាកហើយ ។

ធានី ៖ លំបាកយ៉ាងម៉េច?

ផាន ៖ លំបាកគេប្រើ គេធ្វើក៏យើងចេះតែទៅ ។

ធានី ៖ មីងដែលឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

ផាន ៖ ទេ! មិនដែលដឹង ។

ធានី ៖ ចុះដឹងថាខ្មែរក្រហមជាអ្នកណា?

ផាន ៖ មិនជាស្គាល់ទេ ។

ធានី ៖ មីងនៅភ្នំពេញរាល់ថ្ងៃ មានតុលាការមួយ ហៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយតុលាការនឹង គេកាត់ទោសតែអ្នកដឹកនាំជាន់ខ្ពស់នៅសម័យខ្មែរក្រហម ។ អ្នកដែល ធ្វើការខ្ពស់ៗនៅសម័យខ្មែរក្រហម ។ ដល់ពេលចឹង តុលាការនឹងបានកាត់ទោសរាល់ថ្ងៃនឹង គេហៅមនុស្ស៥រូប ឲ្យនៅតុលាការនឹង មានឌុច, នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ ។ មីងដែលឮឈ្មោះអ្នកអស់នឹង?

ផាន ៖ អត់ដែលឮ ។

ធានី ៖ ពួកគាត់ជាអ្នកធ្វើដឹកនាំជាន់ខ្ពស់នៅសម័យនឹង ។ ហើយគេយកពួកគាត់មកកាត់ទោស ។ ហើយគេទើបនឹងកាត់ទោសហើយ លោក ឌុច នឹង គាត់ជាប្រធានគុកទួលស្លែង បានគេ យកមកកាត់ទោសហើយ ។ ហើយឥឡូវនៅសល់៤នាក់ទៀត ដែលគេនឹងកាត់ទោសគាត់ ទៀត ដែលខ្ញុំនឹងប្រាប់មិញ មាន៤នាក់ទៀត គឺមានលោក អៀង សារី រដ្ឋមន្ត្រីក្រសួង ការបរទេស ហើយលោកស្រី អៀង ធីរិទ្ធ គាត់ជាប្រពន្ធ អៀង សារី ហើយគាត់ជា ប្រធានក្រសួងសង្គមកិច្ច ហើយនួន ជា ជាប្រធានរដ្ឋសភា ហើយនឹង ខៀវ សំផន ជា ប្រមុខរដ្ឋសម័យខ្មែរក្រហមមិនមែនឥឡូវ

គេយកអ្នកទាំង៤នាក់យកមកកាត់ទោសក្នុងពេល តែមួយ ។
ដល់ពេលពួថាមានតុលាការកាត់ទោសមេដឹកនាំខ្ពស់ៗចឹង មីងយល់ថាម៉េច ដែរ?

ដាន : ដឹងយល់ថាម៉េច ។

ធានី : ចឹងមីងមានអីចង់សួរខ្ញុំបន្ថែមទៀតទេ?

ដាន : ទេ! អត់មានចង់សួរអី ។

ធានី : ចឹងខ្ញុំអរគុណមីងណា ។

ដាន : ចា៎!

«ចប់»